

# ការពិនិត្យស្បូនរបៀបផែបតែស្ត
(Pap Tests)

## ជាទម្លាប់ដែលធ្វើឱ្យមានសុខភាពល្អសំរាប់ជីវិត

# Pap Tests:
## *A Healthy Habit for Life*



ចូរអ្នកធ្វើការណាត់សំរាប់ពិនិត្យស្បូនរបៀបផែបតែស្តក្នុងថ្ងៃនេះ!

១. តើខ្ញុំអាចកើតជម្ងឺមហារីក កស្បូនដោយមិនដឹងខ្លួនបានដែរឬ?
ចាស៎! ព្រោះភាគច្រើនមិនមានការឈឺចាប់អ្វីទេ។ ហើយជម្ងឺមហារីកប្រភេទនេះ បានសម្លាប់ស្ត្រីជាច្រើនក្នុងមួយឆ្នាំៗ ជារៀងរាល់ឆ្នាំ។

២. តើវាមានន័យដូចម្តេចសំរាប់ខ្ញុំ?
មានន័យថាៈ អ្នកត្រូវទៅពិនិត្យស្បូនរបៀបផែបតែស្ត។ ការពិនិត្យស្បូនរបៀបផែបតែស្ត អាចរកឃើញជម្ងឺមហារីកដែលទើបកើតមានថ្មីៗ។ ហើយប្រសិនបើរកឃើញជម្ងឺនោះនៅថ្មីៗ វាងាយស្រួលក្នុងការព្យាបាលឲ្យបានជាសះស្បើយ។

៣. តើខ្ញុំត្រូវទៅពិនិត្យស្បូនរបៀបផែបតែស្តនេះ ញឹកញាប់ប៉ុណ្ណាដែរ?
អ្នកត្រូវទៅពិនិត្យស្បូនរបៀបផែបតែស្តនេះជារៀងរាល់ឆ្នាំ ហើយក្នុងមួយឆ្នាំម្តង។

៤. តើការពិនិត្យស្បូនរបៀបផែបតែស្តហ្នឹង ធ្វើដោយរបៀបណាដែរ?
គិលានុបដ្ឋាយិកាឬគ្រូពេទ្យ ប្រើបន្ទះស្តើងតូចមួយកោសយកកោសិកាពី កស្បូនក្នុងរន្ធយោនី។ វិធីនេះ ប្រើពេលតែពីរឬបី វិនាទីប៉ុណ្ណោះ។

Get your appointment for a Pap test today!

1. **Could I have cancer of the cervix and not know it?**

   *Yes—often there is no pain. And this kind of cancer kills many women every year.*

2. **What does that mean for me?**

   *It means get a Pap test. A Pap test can find cancer early. If it's found early, it's easier to cure.*

3. **How often should I get a Pap test?**

   *Get a Pap test every year.*

4. **How is the Pap test done?**

   *The nurse or doctor wipes a swab on the cervix in your vagina. This takes only a few seconds.*



៥. តើខ្ញុំទៅពិនិត្យស្បូនរបៀបផែបតែស្ដនេះនៅឯណា?

- គ្រូពេទ្យប្រចាំគ្រួសារ
- គ្រូពេទ្យដែលមានឯកទេសខាងស្ដ្រីមានផ្ទៃពោះ បង្កើតកូន ឬជម្ងឺស្ដ្រីភេទ
- មន្ទីរពិនិត្យរោគ
- ក្រសួងសុខាភិបាលតាមតំបន់ដែលអ្នករស់នៅ

៦. តើអ្នកណាខ្លះត្រូវពិនិត្យស្បូនរបៀបផែបតែស្ដនេះ?

អ្នកត្រូវពិនិត្យស្បូនរបៀបផែបតែស្ដនេះ បើ៖

- អ្នកមានអាយុច្រើនជាង១៨ឆ្នាំ ឬ
- អ្នកមានអាយុ១៨ឆ្នាំ ឬតិចជាងហើយមានការសេពកាម

មិនមានកំរិតអាយុចំណាស់សំរាប់ការពិនិត្យស្បូនរបៀបផែបតែស្ដនេះទេ។ ទោះបីស្ដ្រីដែលបានឆ្លងកាត់ភាពផ្លាស់ប្ដូរក្នុងឆាកជីវិត ដូចជាការអស់រដូវក្ដី ក៏ត្រូវទៅពិនិត្យស្បូនរបៀបផែបតែស្ដនេះ ឲ្យបានទៀងរាល់ឆ្នាំដែរ។

៧. តើការពិនិត្យស្បូនរបៀបផែបតែស្ដនេះ មានសារៈសំខាន់អ្វីសំរាប់ខ្ញុំ?

ព្រោះវាអាចប្រាប់អ្នកទាន់ពេល បើអ្នកទើបតែកើតជម្ងឺមហារីក កស្បូនថ្មីៗពេលនេះហើយ ដែលធ្វើឲ្យងាយស្រួលក្នុងការព្យាបាលឲ្យបានជាសះស្បើយ។

វាអាចជួយជីវិតអ្នកបាន!

**5. Where do I get a Pap test?**

- *Family doctor*
- *OB/GYN*
- *Medical clinic*
- *Local health department*

**6. Who needs to have a Pap test?**

*You do if:*

- *You are over 18; or*
- *You are 18 or under and have sex*

**There is no upper age limit for the Pap test.**

*Even women who have gone through the change of life (menopause) need a Pap test every year.*

**7. Why is the Pap test important to me?**

*Because it can tell if you have cancer of the cervix early – while it's still easier to cure.*

***It can save your life!***









ចូរទូរសព្ទទៅគ្រូពេទ្យប្រចាំគ្រួសារ ឬមន្ទីរពិនិត្យរោគនៅតាមតំបន់របស់អ្នក នៅក្នុងថ្ងៃនេះ ដើម្បីធ្វើការណាត់សំរាប់ពិនិត្យស្បូនរបៀបផែបតេស្ត។

ការណាត់ពិនិត្យស្បូនរបៀបផែបតេស្តរបស់ខ្ញុំ:

ថ្ងៃខែ: ______________________

ពេលវេលា: ______________________

ទីកន្លែង: ______________________

លេខទូរសព្ទ: ______________________

**Call your family doctor or local medical clinic TODAY for a Pap test appointment.**

*My appointment for a Pap test:*

Date: ______________________

Time: ______________________

Place: ______________________

Telephone: ______________________

Adapted and translated from NIH Publication No. 98-3213.
Funding for development of this pamphlet: NCI AANCART CA86322.

This booklet is not currently available for general distribution.

FRED HUTCHINSON CANCER RESEARCH CENTER
HARBORVIEW MEDICAL CENTER
AANCART